ពេលវេលាគម្រោង

យើងនៅទីនេះ៖

ការអនុម័តដោយអ្នកបោះឆ្នោត — 2016

ការធ្វើផែនការ 2018-2022

- ការបង្កើតជម្រើសផ្សេងទៀត
- ក្រុមប្រឹក្សា ST កំណត់នូវជម្រើសនានាទៅតាមការចង់បាន
- សេចក្តីព្រាងលើរបាយការណ៍ស្តីពីផលប៉ះពាល់បរិស្ថាន
- របាយការណ៍ស្តីពីផលប៉ះពាល់បរិស្ថានសម្រេចចុងក្រោយ
- គំនូសប្លង់ដំណាក់កាលដំបូង
- ក្រុមប្រឹក្សា ST ជ្រើសរើសគម្រោងដែលត្រូវសាងសង់
- កំណត់ត្រាសេចក្តីសម្រេចរបស់សហព័ន្ធ

ការចូលរួមជាសាធារណៈ

គំនូសប្លង់ 2022-2025

- គំនូសប្លង់ផ្លូវរត់សម្រេចចុងក្រោយ
- គំនូសប្លង់ស្ថានីយចុងក្រោយ
- ស្ថានីយលទ្ធកម្មនិងគណៈកម្មការ និងសិល្បៈសាធារណៈ
- ត្រូវមានលិខិតអនុញ្ញាតប្រើប្រាស់ដី និងលិខិតអនុញ្ញាតសាងសង់

ការចូលរួមជាសាធារណៈ

ការសាងសង់ 2025-2030

- ការសន្ទនាជាមួយម្ចាស់អចលនទ្រព្យ
- ការចុះបឋមសិលាសាងសង់
- បច្ចុប្បន្នភាពព័ត៌មានសាងសង់ និងការកាត់បន្ថយផលប៉ះពាល់
- ការអប់រំអំពីសុវត្ថិភាព
- ការធ្វើតេស្ត និងការត្រៀមរៀបចំទុកជាមុន

ការចូលរួមជាសាធារណៈ / ការធ្វើតេស្ត

ការចាប់ផ្តើមសេវាកម្ម — 2030

សូមចូលរួមក្នុងកិច្ចការនេះ

Sound Transit ប្តេជ្ញាចិត្តដើម្បីឲ្យមានការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យខ្លឹមសារ។ យើងនឹងធ្វើការរៀបចំសិក្ខាសាលានិងកិច្ចប្រជុំស្តាប់យោបល់ ដែលមានការចូលរួមដោយតំណាងសហគមន៍ និងរៀបចំតារាងព័ត៌មាននៅតាមពិព័រណ៌និងពិធីបុណ្យជាច្រើននៅក្នុងដំណាក់កាលនៃការត្រួតពិនិត្យបរិស្ថានទាំងមូល ដើម្បីឲ្យអ្នកបានដឹងអំពីបញ្ហាចំណុចខ្វះខាតដែលចាត់ទុកជាជម្រើសសម្រាប់ធ្វើការសិក្សាបន្ថែម។

សមធម៌ និងបរិយាបន្ន

Sound Transit ប្តេជ្ញាចិត្តក្នុងការដាក់ឲ្យមានការចូលរួមពីអ្នកទាំងឡាយដែលរស់នៅនិងធ្វើការនៅក្នុងច្រករបៀងនៃគម្រោង ដោយរួមបញ្ចូលនូវសហគមន៍ដែលមិនទទួលបានការផ្តល់សេវាជិតដល់កាលពីពេលកន្លងមក។ តាមរយៈការធ្វើផែនការ និងការត្រួតពិនិត្យបរិស្ថាន យើងកំពុងធ្វើការយ៉ាងជិតស្និតជាមួយនឹងសហគមន៍ទាំងអស់នេះ ដើម្បីធ្វើការកំណត់និងស្វែងយល់អំពីអត្ថប្រយោជន៍និងផលប៉ះទៅអនាគត និងដើម្បីផ្តល់ឱកាសនានាសម្រាប់ឲ្យមានការចូលរួមដែលមានអត្ថន័យខ្លឹមសារ។

soundtransit.org/tdlink

ទំនាក់ទំនងមកកាន់យើងខ្ញុំ

tdlink@soundtransit.org ឬ 206-398-5453

401 S. Jackson St., Seattle, WA 98104
1-800-201-4900 / TTY បញ្ជូនបន្ត៖ 711

ព័ត៌មានក្នុងទ្រង់ផ្សេងទៀត៖
1-800-201-4900 / TTY បញ្ជូនបន្ត៖ 711
អ៊ីម៉ែល៖ accessibility@soundtransit.org

Para información acerca del proyecto llame al 1-800-823-9230.

要瞭解項目資訊，請致電：1-800-823-9230.

За информацией об этом проекте обращайтесь по телефону 1-800-823-9230.

프로젝트에 관한 정보를 위해, 1-800-823-9230로 전화 부탁드립니다.

Để biết thông tin về dự án, hãy gọi: 1-800-823-9230.

សម្រាប់ព័ត៌មានអំពីគម្រោង សូមហៅទៅលេខ 1-800-823-9230.

តាមដានយើង៖

SoundTransit

Tacoma Dome Link Extension

ផ្លូវដែកល្បឿនលឿនក្នុងតំបន់កំពុងដាក់ឲ្យដំណើរការ

ស្ថានភាពគម្រោងបច្ចុប្បន្ន៖ ការត្រួតពិនិត្យលើបរិស្ថាន (2019–2022)

កក្កដា 2019៖ ក្រុមប្រឹក្សា Sound Transit បានកំណត់ផ្លូវរត់និងទីតាំងស្ថានភាពដើម្បីធ្វើការសិក្សានៅក្នុងសេចក្តីព្រៀងរបាយការណ៍ស្តីពីផលប៉ះពាល់បរិស្ថាន (Environmental Impact Statement, EIS)។ EIS នឹងធ្វើការវាយតម្លៃលើផលប៉ះពាល់ធំៗ និងអត្ថប្រយោជន៍ទៅអនាគតនៃគម្រោងនេះ ចំពោះបរិស្ថានធម្មជាតិ និងបរិស្ថានសិប្បនិម្មិត និងកំណត់វិធានការកាត់បន្ថយផលប៉ះពាល់ធំៗ។ **Sound Transit** មានគម្រោងក្នុងការបញ្ចេញសេចក្តីព្រៀង **EIS** ស្រមាប់ការត្រួតពិនិត្យជាសាធារណៈ និង

អំពីគម្រោងនេះ

Tacoma Dome Link Extension (TDLE) នឹងផ្តល់ការភ្ជាប់ផ្លូវដែកល្បឿនលឿនដែលឆាប់រហ័សនិងអាចជឿទុកចិត្តបានជូនដល់មជ្ឈមណ្ឌលលំនៅដ្ឋាន និងមជ្ឈមណ្ឌលការងារនៅក្នុងតំបន់ South Sound។ ការពង្រីកខ្សែផ្លូវដែក គឺជាផ្នែកនៃការពង្រីកប្រព័ន្ធដឹកជញ្ជូនដែលមានការអនុម័តដោយអ្នកបោះឆ្នោតនៅក្នុងខែវិច្ឆិកា ឆ្នាំ2016។ នៅពេលបញ្ចប់ អ្នកជិះរថភ្លើង នឹងអាចធ្វើដំណើរពី South Federal Way ទៅកាន់ Tacoma Dome ក្នុងរយៈពេល 20 នាទី ហើយពី Tacoma Dome ទៅកាន់ព្រលានយន្តហោះ Sea-Tac Airport ក្នុងរយៈពេល 35 នាទី។

ផែនទីគម្រោងនៅផ្នែកខាងក្នុង

SoundTransit / *Powering progress*

2017–2019

តើយើងអាចធ្វើដំណើរមកទីនេះដោយរបៀបណា?

ចាប់ពីឆ្នាំ 2017–2019, គម្រោងនេះ ស្ថិតនៅក្នុងដំណាក់កាលនៃការបង្កើតជម្រើសនានា — រយៈពេលមួយដែលរួមមាននូវការវិភាគបច្ចេកទេស ការផ្ដល់យោបល់ពីសហគមន៍ និងការផ្ដល់អនុសាសន៍ពីក្រុមភាគីពាក់ព័ន្ធ និងក្រុមថ្នាក់ដឹកនាំដែលត្រូវបានបោះឆ្នោតជ្រើសរើស ដើម្បីបង្រួមជម្រើសនេះឲ្យកាន់តែតូច។ តើមានលទ្ធផលយ៉ាងដូចម្ដេច? បន្ទាប់ពីការសិក្សាយ៉ាងទូលំទូលាយលើផ្លូវរត់ និងទីតាំងស្ថានីយ ក្រុមប្រឹក្សា Sound Transit បានកំណត់នូវជម្រើសតាមការចង់បាន និងជម្រើសដទៃផ្សេងទៀតដើម្បីធ្វើការសិក្សានៅក្នុងសេចក្ដីព្រៀង EIS ផ្អែកលើមតិយោបល់ដែលទទួលបានការពីការចូលរួមយោបល់ពីសាធារណៈជនក្នុងរយៈពេលជិត 18 ខែ។

2019–2022

តើមានអ្វីបន្ទាប់ទៀត?

បច្ចុប្បន្ននេះ គម្រោងនេះកំពុងស្ថិតក្នុងការត្រួតពិនិត្យបរិស្ថាន និងគំនូសប្លង់ដំណាក់កាលដំបូង។ ឱកាសបន្ទាប់របស់អ្នកដើម្បីដាក់ជូនមតិយោបល់អំពីផ្លូវរត់និងទីតាំងស្ថានីយពី Federal Way ទៅ Tacoma នឹងត្រូវធ្វើឡើងនៅឆ្នាំ 2021 នៅពេលយើងចុះផ្សាយសេចក្ដីព្រៀង EIS។ នៅពេលទទួលបានដំណឹងពីការផ្ដល់មតិយោបល់ដែលទទួលបានដោយសាធារណជន ទីភ្នាក់ ងារនានា និងក្រុមកុលសម្ព័ន្ធ ក្រុមប្រឹក្សា Sound Transit នឹងធ្វើការបញ្ជាក់ ឬធ្វើការកែប្រែជម្រើសទៅតាមការចង់បាន។ បន្ទាប់មកទៀត យើងនឹងធ្វើការរៀបចំ EIS សម្រេចចុងក្រោយ ដើម្បីធ្វើការសិក្សាអំពីជម្រើសទៅតាមការចង់បាន ជាមួយនឹងជម្រើសដទៃផ្សេងទៀត និងធ្វើការឆ្លើយតបចំពោះមតិយោបល់ដែលទទួលបនអំពីសេចក្ដីព្រៀង EIS។ បន្ទាប់ពីយើងចុះផ្សាយ EIS សម្រេចចុងក្រោយនៅក្នុងឆ្នាំ 2022, ក្រុមប្រឹក្សា Sound Transit នឹងធ្វើការជ្រើសរើសនូវផ្លូវរត់ចុងក្រោយ និងទីតាំងស្ថានីយដែលត្រូវសាងសង់។

សកម្មភាពក្នុងពេលបន្ទាប់

ការងារនៅមូលដ្ឋាន ក្រុមគម្រោង ធ្វើផែនការដើម្បីចុះធ្វើការងារមួយចំនួននៅមូលដ្ឋាននៅតាមរបៀបផ្លូវ។ តើអ្វីទៅជាការងារមូលដ្ឋាន? វាគឺជាការស្រាវជ្រាវដ៏មានសារៈសំខាន់ដែលអាចរួមបញ្ចូលនូវការស្ទង់មតិ និងខួងដីប្រមូលយកសំណាកគំរូដី និងធ្វើតេស្ដរំញ័រ និងគ្រប់គ្រងសំឡេង និងច្រើនទៀត។

ការធ្វើផែនការស្ថានីយ។ ការសាងសង់ផ្លូវរត់ភ្លើងល្បឿនលឿន គឺមិនគ្រាន់តែដើម្បីបម្លាស់ទីមនុស្សពីកន្លែងមួយទៅកន្លែងមួយនោះទេ វាក៏ពាក់ព័ន្ធនឹងការកសាងសហគមន៍ផងដែរ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ យើងនឹងធ្វើការជាមួយសហគមន៍នានានៅតាមច្រករបៀបគម្រោង ដើម្បីជួយផ្ដល់ព័ត៌មានអំពីការបង្កើតគំនូសប្លង់ស្ថានីយ។ វាគឺជាគោលដៅរបស់យើងក្នុងការកំណត់អំពីដំណោះស្រាយដែលស័ក្ដិសមបំផុតទៅនឹងចក្ខុវិស័យសម្រាប់សហគមន៍របស់អ្នកនិងភ្ជាប់មនុស្សកាន់តែច្រើនជាមួយនឹងប្រព័ន្ធដឹកជញ្ជូនធំៗ។

ផ្លូវរត់និងទីតាំងស្ថានីយដែលកំពុងត្រូវបានសិក្សានៅក្នុងសេចក្ដីព្រៀង EIS



ចុះឈ្មោះដើម្បីទទួលបានអ៊ីម៉ែលអំពីគម្រោង និងស្វែងយល់បន្ថែមអំពីរបៀបចូលរួម៖

soundtransit.org/tdlink

2030 Federal Way ទៅ Tacoma

- បន្ថែម 9.7 ម៉ាយ នៃសេវាដឹកជញ្ជូនផ្លូវដែកល្បឿនលឿនពីមជ្ឈមណ្ឌលដឹកជញ្ជូន Federal Way ទៅកាន់តំបន់ស្ថានីយ Tacoma Dome។
- ស្ថានីយថ្មីៗចំនួនបួននៅ South Federal Way, Fife, ភាគខាងកើតនៃ Tacoma និងនៅតំបន់ Tacoma Dome។
- ផ្ដល់នូវការភ្ជាប់ទៅកាន់សេវាដឹកជញ្ជូនដទៃផ្សេងទៀតនៅក្នុងតំបន់ដូចជា Sounder, Tacoma Link, Sound Transit Express, King County Metro, Pierce Transit, Intercity Transit និង Amtrak។
- កម្មវិធីពិសេសនានាដើម្បីយកភ្ញៀវនិងដាក់ចុះនៅតំបន់នានា និងផ្ដល់នូវការចូលទៅកាន់កន្លែងដែលអាចធ្វើដំណើរថ្មើរជើង ជិះកង់ សេវាដឹកជញ្ជូនសម្រាប់ជនពិការ និងមធ្យោបាយដទៃផ្សេងទៀត។
- រួមបញ្ចូលនូវកន្លែងចំណតថ្មីចំនួនពីរនៅ South Federal Way និង Fife។

SOUNDTRANSIT